# ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម ( ផ្លូវលេខ ១១៣បេ )
សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ ( ៨៥៥-២៣) ៨៦៦ ៤៦៩
ទូរសារ ( ៨៥៥) ០២៣ ៨៦៦ ៤៦៩
គេហទំព័រ www.moc.gov.kh

# វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម

| | |
|---|---|
| ឈ្មោះសេវា | វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម |
| ក្រសួង / ស្ថាប័នផ្តល់សេវា | ក្រសួងពាណិជ្ជកម្ម<br>នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម<br>ឡូតិ៍លេខ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម(ផ្លូវលេខ១១៣បេ) សង្កាត់ទឹកថ្លា<br>ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>ទូរស័ព្ទ ០២៣ ៨៦៦ ០៥០<br>អ៊ីម៉ែល : d.reg_moc@yahoo.com |
| គោលបំណង<br>នៃការផ្តល់សេវា | - ផ្តល់នីតិបុគ្គលិកលក្ខណៈជូនដល់សហគ្រាសពាណិជ្ជកម្មដោយចេញជូននូវវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ។<br>- កាន់កាប់បញ្ជីពាណិជ្ជកម្មគ្រប់គ្រងទិន្នន័យ ឈ្មោះក្រុមហ៊ុន-សហគ្រាសពាណិជ្ជ- កម្ម ។<br>- ចុះបញ្ជីពាណិជ្ជកម្ម និងគ្រប់គ្រងសមត្ថភាពសហគ្រាស-ក្រុមហ៊ុនពាណិជ្ជកម្ម ។ |
| មូលដ្ឋានគតិយុត្ត | - ព្រះរាជក្រមលេខ នស / រកម / ០៦៩៥ / ០៤ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើនូវច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម<br>- ព្រះរាជក្រមលេខ នស / រកម / ១១៩៩ / ១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីការប្រកាសឱ្យប្រើនូវច្បាប់ស្តីពីវិសោធនកម្ម លើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។<br>- ព្រះរាជក្រមលេខ នស / រកម / ០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការប្រកាសឱ្យប្រើនូវច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។<br>- ប្រកាសលេខ ០៩៨ MOC / SM 2008 ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៨ ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ។<br>- ប្រកាសលេខ ១០៤ MOC / SM 2008 ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៨ ស្តីពីការបំពេញប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម<br>- ប្រកាសលេខ ០៩៩ MOC / SM 2008 ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៨ ស្តីពីបែបបទ និងនីតិវិធីកែប្រែលក្ខន្តិកៈក្រុមហ៊ុនរបស់ក្រសួងពាណិជ្ជកម្ម ។<br>- ប្រកាសអន្តរក្រសួងលេខ ៦៧៩ សហវ.ប្រក.ចមព ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០០៧ ស្តីពីកំណែទម្រង់រដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ |

| | |
|---|---|
| | - សេចក្តីជូនដំណឹង លេខ ០៥៥១ MOC/SM ២០០៨ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ ២០០៨ ស្តីពីបែបបទទំនាក់ទំនង និងរយៈពេលចុះបញ្ជីនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ។<br>- សេចក្តីជូនដំណឹងលេខ ០៨៤៩ MOC / SM 2008 ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០០៨ ស្តីពីការមកប្តូរយកវិញ្ញាបនបត្រចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមគំរូថ្មី និងការមកបំពេញប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជ-កម្ម ។<br>- សេចក្តីជូនដំណឹងលេខ ០៨៤៤ MOC/SM 2008 ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០០៨ ស្តីពីការតម្កល់ដើមទុនក្រុមហ៊ុននៅធនាគាររបស់ក្រសួងពាណិជ្ជកម្ម ។<br>- សេចក្តីជូនដំណឹងលេខ ៣៧៧៣ ពណ.ចបព ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការផ្តល់អត្តលេខចុះបញ្ជីពាណិជ្ជកម្មថ្មី ។ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | រូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងឡាយដែលធ្វើពាណិជ្ជកិច្ច ហើយដែលយកពាណិជ្ជកិច្ច នេះជាមុខរបរខ្លួនជាប្រចាំ ។ |
| ស្តង់ដារសេវា | - ការផ្តល់សេវាចុះបញ្ជីពាណិជ្ជកម្មប្រព្រឹត្តទៅដោយអនុលោមតាមច្បាប់ ស្តីពីវិធាន ពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ហើយសម ស្របទៅតាមទម្រង់ការ នៃការចុះបញ្ជីពាណិជ្ជកម្មនៃបណ្តាប្រទេសនានា លើ សកលលោក ឧទាហរណ៍ការពិនិត្យនាមករណ៍សហគ្រាសក្រុមហ៊ុនដែលស្នើសុំចុះ បញ្ជី និងការបដិសេធចុះបញ្ជីចំពោះនាមករណ៍ណាដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នាទៅនឹងនាមករណ៍ដែលបានចុះបញ្ជីរួចហើយ ។ ល ។<br>- ជាទូទៅ ការចុះបញ្ជីពាណិជ្ជកម្មប្រើរយៈពេលពី ៣ ទៅ ៥ថ្ងៃ ក្នុងករណីសំណុំឯកសារស្នើសុំចុះបញ្ជីពាណិជ្ជកម្មត្រូវបានបំពេញគ្រប់គ្រាន់តាមការតម្រូវ ។<br>- កម្រៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្មត្រូវបានកំណត់ដូចតទៅ :<br>១-សហគ្រាសឯកបុគ្គល ឬពាណិជ្ជករដែលជាប់ពន្ធលើប្រាក់ចំណេញ :<br>- ចុះបញ្ជីពាណិជ្ជកម្ម តម្លៃ ................................... ១២០.000 រៀល<br>- លុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម តម្លៃ ..................៦០.000 រៀល<br>- សុំវិញ្ញាបនបត្រផ្សេងទៀត តម្លៃ ............................២០.000 រៀល<br>២-ក្រុមហ៊ុនពាណិជ្ជកម្ម:<br>- ចុះបញ្ជីពាណិជ្ជកម្ម តម្លៃ ................................... ៤២០.000 រៀល<br>- លុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម តម្លៃ .................២០០.000 រៀល |

| | |
|---|---|
| | - ស៊ុំវិញ្ញាបនបត្រផ្សេងទៀតតម្លៃ ............................៦០.០០០ រៀល |
| តម្រូវការឯកសារ | ១-សហគ្រាស<br>- ពាក្យស្នើសុំចុះបញ្ជី ............................................................០៣ ច្បាប់<br>- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លងរបស់ឯកកម្មសិទ្ធិករ.....០៣ សន្លឹក<br>- រូបថត ៤ x ៦ របស់ឯកកម្មសិទ្ធិករ.......................................០៣ សន្លឹក<br>២-ក្រុមហ៊ុន<br>- ពាក្យស្នើសុំចុះបញ្ជី..............................................................០៣ ច្បាប់<br>- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លងរបស់ម្ចាស់ហ៊ុន<br>និងអភិបាលទាំងអស់ម្នាក់ .....................................................០៣សន្លឹក<br>- រូបថត ៤ x ៦ របស់ម្ចាស់ហ៊ុន និងអភិបាលទាំងអស់ ម្នាក់..........០៣សន្លឹក<br>- លិខិតធនាគារបញ្ជាក់ការតម្កល់ប្រាក់ ៤លានរៀល......................០១ច្បាប់ដើម<br>- លក្ខន្តិកៈ.........................................................................០៣ច្បាប់ |
| យោបល់ | រាល់ពាណិជ្ជករនិងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយដែលមានគ្រឹះស្ថានរបស់ខ្លួនសាខាការិយាល័យតំណាងបុត្រសម្ព័ន្ធ<br>ឬទីភ្នាក់ងាររបស់ខ្លួននៅព្រះរាជាណាចក្រកម្ពុជាត្រូវ<br>ប្រញាប់រូតរះមកចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃ ក្រសួងពាណិជ្ជកម្មស្របទៅតាមច្បាប់ជាធរមាន។<br>ក្នុងករណីខកខាននឹងត្រូវផ្តន្ទា ទោសទៅតាមការកំណត់របស់ច្បាប់ ។ |

# ចុះបញ្ជីម៉ាក និងម៉ាកទំនិញសម្គាល់ភូមិសាស្ត្រ

| | |
|---|---|
| ឈ្មោះសេវា | ១-ចុះបញ្ជីម៉ាក<br>២-ម៉ាកទំនិញសម្គាល់ភូមិសាស្ត្រ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងពាណិជ្ជកម្ម<br>នាយកដ្ឋានកម្មសិទ្ធិបញ្ញា<br>ឡូត៍លេខ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (ផ្លូវលេខ១១៣បេ) សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : (៨៥៥) ២៣ ៨៦៦ ១១៥<br>ទូរសារ : (៨៥៥) ២៣ ៨៦៦ ១១៤<br>អ៊ីម៉ែល : dipr.moc@gmail.com |
| គោលបំណង<br>នៃការផ្តល់សេវា | ការពារម៉ាក ពាណិជ្ជនាម និងម៉ាកទំនិញសម្គាល់ភូមិសាស្ត្រ ដែលបានចុះក្នុងបញ្ជីម៉ាក នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រឆាំងការប្រកួតប្រជែងមិនស្មោះត្រង់លើការ បង្កើត ការប្រើប្រាស់ម៉ាក ពាណិជ្ជនាម និងម៉ាកទំនិញសម្គាល់ភូមិសាស្ត្រ និងជា ពិសេសជួយជំរុញ និងការពារសហគ្រាសធុនតូច និងមធ្យម សមាគមផលិតករឱ្យផលិតទំនិញបានច្រើនបម្រើដល់តម្រូវការក្នុងប្រទេស និងអាចឈានឡើងដល់ការនាំចេញ និងទាក់ទាញវិនិយោគពីបរទេស ។ |
| មូលដ្ឋានគតិយុត្ត | ១- ព្រះរាជក្រមលេខ នស/រកប/0២0២/00៦ ចុះថ្ងៃទី0៧ ខែកុម្ភៈ ឆ្នាំ២00២ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ។<br>២- អនុក្រឹត្យ លេខ ៦៤អនក្រ.បក ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២00៦ ស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ។<br>៣- ប្រកាសអន្តរក្រសួងលេខ ៤៥៧ សហវ.ប្រកចមព ចុះថ្ងៃទី 0៨ ខែមិថុនា ឆ្នាំ ២00៧ ស្តីពីកម្រៃរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានារបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។<br>៤- ប្រកាសលេខ ១0៥ MOC / SM 2009 ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២00៩ ស្តីពី<br>នីតិវិធីណែនាំការចុះបញ្ជី និងការការពារម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រ ។ |
| អតិថិជនដែលមានសិទ្ធិ | រូបវន្តបុគ្គល និង នីតិបុគ្គល |

| | |
|---|---|
| ទទួលសេវា | |
| ស្តង់ដារសេវា | - ការផ្តល់សេវាចុះបញ្ជីម៉ាកនៅព្រះរាជាណាចក្រកម្ពុជាស្របតាមស្តង់ដារអន្តរជាតិ ដែលអង្គការកម្មសិទ្ធិបញ្ញាពិភពលោកបានផ្តល់នូវប្រព័ន្ធ IPAS ប្រើប្រាស់ជាមួយ Computer ដែលពិនិត្យម៉ាកតាមជំហាននីមួយៗ ដែលរួមមានអត្ថន័យ សម្លេងអាន រូបភាពមើលឃើញ (Appearance) និងធ្វើការប្រៀបធៀបមុខទំនិញ និងសេវាដែលដូច ឬប្រហាក់ប្រហែល ឬមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។ ទន្ទឹមនេះ ត្រូវពិនិត្យមើលពាក្យស្លោក ពាក្យទូទៅ (Generic term) ប្រភេទ (Kind) បរិមាណ (Quantity) គុណភាព (Quality) និងចំណុចផ្សេងៗជាច្រើនទៀតតាម ស្តង់ដារអន្តរជាតិ ។<br>- ចុះបញ្ជីម៉ាកនៅព្រះរាជាណាចក្រកម្ពុជាមានរយៈពេល ០៣ ទៅ ០៤ខែ ឬលើសពីរយៈពេលនេះ ក្នុងករណីមានភាគីទីបីជំទាស់ ឬការទទួលពាក្យមានការកើនឡើងច្រើន ឬការកែតម្រូវពាក្យស្នើសុំរបស់អ្នកដាក់ពាក្យ បើប្រៀបធៀបទៅនឹង ការចុះបញ្ជីម៉ាកនៅបណ្តាប្រទេសអាស៊ានមានរយៈពេលចាប់ពី ៦ ខែ ទៅ ១២ ខែ ចំណែកឯនៅសហរដ្ឋអាមេរិកមានរយៈពេល ១២ ខែ ទៅ១៨ ខែ ។<br>❖ **កម្រៃនៃការចុះបញ្ជីម៉ាកមានដូចខាងក្រោម :**<br>I-<u>ការចុះបញ្ជីម៉ាក</u><br>១- ការដាក់ពាក្យសុំចុះបញ្ជីម៉ាក សម្រាប់មួយម៉ាក និងមួយជំពូកមានតម្លៃ ..........................................................................២០.០០០ រៀល<br>២- ការចុះបញ្ជីម៉ាក ដែលមានសុពលភាព ១០ ឆ្នាំ សម្រាប់មួយម៉ាក និងមួយជំពូក មានតម្លៃ....................................................១៨០. ០០០ រៀល<br>៣- កម្រៃរដ្ឋបាលក្នុងការបោះពុម្ពផ្សាយម៉ាក ដែលបានចុះបញ្ជីរួចហើយក្នុងព្រឹត្តិបត្រផ្លូវការនឹងត្រូវកំណត់នៅពេលក្រោយ។<br>II-<u>ការបញ្ជាក់ពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក</u><br>ការដាក់ពាក្យ និងការបញ្ជាក់ពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក សម្រាប់មួយម៉ាក និងមួយជំពូក មានតម្លៃ ......................................៤០.០០០ រៀល<br>III-<u>ការផ្លាស់ប្តូរផ្សេងៗ</u><br>-ការកត់ត្រាការផ្ទេរកម្មសិទ្ធម៉ាក (Assignment) សម្រាប់មួយម៉ាក និងមួយ |

| | |
|---|---|
| | ជំពូក មានតម្លៃ ...............................................................៤០.០០០រៀល<br>-ការកត់ត្រា ការប្តូរឈ្មោះ ឬការរួមបញ្ចូលគ្នា នៃម្ចាស់ម៉ាក (Name Change and Merger) សម្រាប់មួយម៉ាក និងមួយជំពូក មានតម្លៃ .......................................................................................៤០.០០០រៀល<br>-ការកែតម្រូវនានា (ជាកំហុសរបស់អ្នកដាក់ពាក្យ) សម្រាប់មួយម៉ាក និងមួយ<br>ជំពូក មានតម្លៃ ...............................................................៤០.០០០រៀល<br>-ការកត់ត្រា ការប្តូរឈ្មោះអាស័យដ្ឋាន (Adress Change) (ក្នុងករណីប្តូរ<br>តែអាស័យដ្ឋានមួយប៉ុណ្ណោះ) សម្រាប់មួយម៉ាក និងមួយជំពូក មានតម្លៃ .......................................................................................៤០.០០០រៀល<br>IV-<u>ការលុបម៉ាក</u><br>-ការលុបម៉ាកចេញពីបញ្ជី (បង់ដោយអ្នកស្នើលុប) មួយវិញ្ញាបនប័ត្រ មានតម្លៃ<br>.......................................................................................២០០.០០០រៀល<br>V-<u>ការចុះបញ្ជីម៉ាកឡើងវិញ</u><br>-ការលុបម៉ាកចេញពីបញ្ជី (បង់ដោយអ្នកស្នើលុប) មួយវិញ្ញាបនបត្រ មានតម្លៃ<br>.......................................................................................២០០.០០០រៀល<br>VI-<u>ការបោះពម្ពផ្សេងទៀត (ប្រសិនបើមាន)</u><br>-ទំហំតូចជាង ១/៣ នៃក្រដាស A4 មួយឯកត្តា មានតម្លៃ.......៤០.០០០រៀល<br>-ទំហំ ១/៣ នៃក្រដាស A4 មួយឯកត្តា មានតម្លៃ.................៨០.០០០រៀល<br>-ទំហំ ១/២ នៃក្រដាស A4 មួយឯកត្តា មានតម្លៃ................១២០.០០០រៀល<br>-ទំហំ ៣/៤ នៃក្រដាស A4 មួយឯកត្តា មានតម្លៃ.................២០០.០០០រៀល<br>-ទំហំក្រដាស A4 មួយឯកត្តា មានតម្លៃ...............................៤០០.០០០រៀល |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | តម្រូវការឯកសារសម្រាប់ចុះបញ្ជីម៉ាក មានដូចខាងក្រោម<br>- ពាក្យស្នើសុំតាមគំរូលេខ ០០១<br>- គំរូម៉ាកបោះពុម្ពឡើងវិញចំនួន ១៥ |

| | |
|---|---|
| | - លិខិតប្រគល់សិទ្ធិតាមគំរូលេខ ០០២ ( ប្រសិនចាត់តាំងភ្នាក់ងារតំណាង) |
| យោបល់ | ដើម្បីជៀសវាងការលួចបន្លំ ឬជម្លោះលើការប្រើប្រាស់ម៉ាកដូច ឬស្រដៀង នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម សូមជម្រាបជូនដល់រូបវន្តបុគ្គល នីតិបុគ្គល អាជីវករ សហគ្រិនទាំងអស់គួរតែយកម៉ាករបស់ខ្លួនមកចុះបញ្ជី ដើម្បីទទួលបានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ដូចខាងក្រោម៖<br>- ចំពោះម៉ាកដែលទាក់ទងនឹងទំនិញ ឬ សេវាដែលបានចុះបញ្ជីរួចហើយការប្រើប្រាស់ម៉ាកនោះដោយជនណាមួយក្រៅពីម្ចាស់ដើមត្រូវមានការយល់ព្រមជាមុនសិន។<br>- ម្ចាស់ដើមនៃម៉ាកមានសិទ្ធិប្តឹងទៅតុលាការប្រឆាំងនឹងជនណាម្នាក់ដែលប្រើប្រាស់ដោយរំលោភនូវម៉ាករបស់ខ្លួន ដោយគ្មានការយល់ព្រមពីម្ចាស់ដើម។<br>ម្ចាស់ដើមក៏មានសិទ្ធិប្តឹងផងដែរ ចំពោះការប្រើប្រាស់នូវសញ្ញាដែលប្រហាក់ប្រហែលនឹងម៉ាកដែលខ្លួនបានចុះបញ្ជីរួចហើយ និងការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនឹងទំនិញ និងសេវាដែលប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវានៃម៉ាកដែលចុះបញ្ជី រួចហើយនោះហើយដែលអាចបណ្តាលឱ្យមានការភ័ន្តច្រឡំជាសាធារណៈ។ ការខកខានមិនបានចុះបញ្ជីការពារម៉ាកអាចនាំដល់ផលវិបាកនានាដូចជា មិនអាចទប់ស្កាត់ ឬប្តឹងទៅអាជ្ញាធរ មានសមត្ថកិច្ចប្រឆាំងនឹងអ្នកប្រើប្រាស់ម៉ាកដែលដូច ឬស្រដៀងនឹងម៉ាករបស់ខ្លួន ដោយគ្មានការអនុញ្ញាត ឬលំបាកក្នុងការផ្ទេរសិទ្ធិប្រើប្រាស់ម៉ាករបស់ខ្លួនទៅអ្នកដទៃ ជាដើម។ |

# វិញ្ញាបនបត្រចុះបញ្ជីនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងវិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ (Certificate of Origin " C/O " )

| | |
|---|---|
| ឈ្មោះសេវា | ១-វិញ្ញាបនបត្រចុះបញ្ជីនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម<br>២-វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ (Certificate of Origin " C/O " ) |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងពាណិជ្ជកម្ម<br>នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម<br>ឡូត៍លេខ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម( ផ្លូវលេខ១១៣បេ) សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៨៦៦ ១៧៣<br>អ៊ីម៉ែល : mak@camnet.com.kh |
| គោលបំណង<br>នៃការផ្តល់សេវា | ១- ផ្តល់នីតិបុគ្គលិកលក្ខណៈជូនដល់សហគ្រាសពាណិជ្ជកម្មដោយចេញជូននូវវិញ្ញាបន - បត្រចុះបញ្ជីនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម<br>២- ចុះបញ្ជី និងគ្រប់គ្រងសមត្ថភាពផលិតកម្មរបស់សហគ្រាស-ក្រុមហ៊ុន ពាណិជ្ជកម្ម<br>៣-ផ្តល់ជូនអ្នកនាំចេញនូវវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (Certificate of Origin " C/O" ) ពីប្រទេសកម្ពុជាទៅទ្វីបអាមេរិក។<br>៤- ផ្សព្វផ្សាយ ឬបំភ្លឺពីវិធានប្រភពដើមទំនិញដល់អ្នកនាំចេញ។ |
| មូលដ្ឋានគតិយុត្ត | • ប្រកាសលេខ 014 ព.ណ បអពប្រក ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការ ចេញវិញ្ញាបនបត្រ ប្រភពដើមទំនិញកម្ពុជាចំពោះទំនិញសំលៀកបំពាក់សម្រាប់នាំ ចេញរបស់ក្រសួងពាណិជ្ជកម្ម។<br>• ប្រកាសលេខ 1695 ព.ណ បអព ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពី ការកំណត់កម្រៃ វិញ្ញាបនបត្រប្រភពដើមទំនិញនាំចេញរបស់ក្រសួងពាណិជ្ជកម្ម<br>• ប្រកាសលេខ 265 MoC / M 2002 ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ ស្តីពី ការផ្តល់វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញជូនអង្គការក្រៅរដ្ឋាភិបាល (NGOs) របស់ក្រសួងពាណិជ្ជកម្ម។<br>• ប្រកាសលេខ 021 MOC / M 2004 ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៤ ស្តីពី ការផ្តល់វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញជូនសិប្បកម្មក្នុងស្រុករបស់ក្រសួង ពាណិជ្ជកម្ម។ |

| | |
|---|---|
| | • ប្រកាសលេខ 159 MOC / M 2004 ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤ ស្តីពី នីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ,វិក្កយបត្រពាណិជ្ជកម្ម, អាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ។<br>• ប្រកាសលេខ 186 ព.ណ បអពប្រក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពី ការកែសម្រួលនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ, វិក្កយបត្រ ពាណិជ្ជកម្ម ។ អាជ្ញាប័ណ្ណនាំចេញតាមជើងយន្តហោះរបស់ក្រសួងពាណិជ្ជកម្ម ។<br>• ប្រកាសលេខ 070 MOC / M 2005 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលនីតិវិធីចេញ វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ, វិក្កយបត្រ ពាណិជ្ជកម្ម, អាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ។<br>• ប្រកាសលេខ 261 MOC / M 2005 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលនីតិវិធីចេញ វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ, វិក្កយបត្រ ពាណិជ្ជកម្ម, អាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ។<br>• ប្រកាសលេខ 104 MOC / M 2005 ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ,វិក្កយបត្រពាណិជ្ជកម្ម តាមជើងយន្តហោះទៅសហរដ្ឋអាមេរិករបស់ក្រសួងពាណិជ្ជកម្ម ។<br>• ប្រកាសលេខ 273 ព.ណ បអពប្រក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពី នីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រសួងពាណិជ្ជកម្ម ។<br>• ប្រកាសលេខ 285 ព.ណ បអពប្រក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៥ ស្តីពី ការកំណត់កម្រៃគ្រប់គ្រងការនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ។<br>• ប្រកាសលេខ 193 MOC/SM 2006 ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៦ ស្តីពី ការបង់កម្លៃគ្រប់គ្រងការនាំចេញសម្រាប់សំលៀកបំពាក់អនាម័យ ដែលប្រើតែមួយលើករួចហើយបោះចោលរបស់ក្រសួងពាណិជ្ជកម្ម ។<br>• ប្រកាសលេខ 176 MOC/SM 2006 ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦ ស្តីពី វិធានការចាំបាច់មួយចំនួនសម្រាប់គ្រប់គ្រងការនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ។<br>• ប្រកាសលេខ 232 MOC/SM 2006 ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការពិន័យចំពោះការយឺតយូរមិនព្រមបង់កម្រៃគ្រប់គ្រង ការនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ។<br>• ប្រកាសលេខ 216 MOC/SM 2007 ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពី |

| | |
|---|---|
| | ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម។<br>• ប្រកាសអន្តរក្រសួងលេខ 044 MOC/SM 2007 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលការកំណត់កំរៃគ្រប់គ្រងការនាំចេញ និងសោហ៊ុយពាក់ព័ន្ធរបស់ក្រសួងពាណិជ្ជកម្ម។<br>• ប្រកាសអន្តរក្រសួងលេខ 097 MOC/SM 2007 ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួល និងការកំណត់កំរៃគ្រប់គ្រងការនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ។<br>• ប្រកាសលេខ 045 MOC/SM 2008 ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការ នាំចេញសំលៀកបំពាក់ ពណិប៉ាវ៉ា ពណិបៃតង (ត្រីអ៊ុ) និងកាតីរបស់ក្រសួង ពាណិជ្ជកម្ម ។<br>• ប្រកាសលេខ 106 MOC / SM 2008 ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០៨ ស្តីពីការផ្តល់វិញ្ញាបនបត្រប្រភពដើមទំនិញតាមជើងយន្តហោះបន្ទាប់ពីដឹកជញ្ជូន តាមរថយន្តឆ្លងកាត់ព្រំដែនកម្ពុជារបស់ក្រសួងពាណិជ្ជកម្ម។<br>• ប្រកាសលេខ 110 MOC/SM 2008 ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០០៨ ស្តីពីការចុះបញ្ជីសុំសិទ្ធិនាំចេញ ក្រោមគម្រោងអនុគ្រោះពន្ធសម្រាប់សហគ្រាសសិប្បកម្មរបស់ក្រសួងពាណិជ្ជកម្ម។<br>• ប្រកាសអន្តរក្រសួងលេខ 274 MOC/SM 2008 ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលការកំណត់កម្រៃគ្រប់គ្រងការនាំចេញ។<br>• ប្រកាសលេខ 179 MOC/SM 2009 ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលនីតិវិធីក្នុងការផ្តល់វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ។ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | នីតិបុគ្គល |
| ស្តង់ដារសេវា | ដោយអនុវត្តទៅតាមខ្លឹមសារប្រកាសលេខ ១៥៩ MOC/M 2004 ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤ ចាប់ពីពេលដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ នៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម រហូតដល់ពេលដែលមកទទួលយកឯកសារ មានរយៈពេល ១១ ម៉ោង ៥៥ នាទី នៅម៉ោងធ្វើការ។ អ្នកនាំចេញ ឬតំណាង ត្រូវ បង្ហាញបង្កាន់ដៃ និងលិខិតប្រគល់សិទ្ធិទើបទទួលយកឯកសារបាន។ |
| តម្រូវការឯកសារ | ១-តម្រូវការឯកសារសម្រាប់ចុះបញ្ជីពាណិជ្ជកម្មនាំចេញក្រោមប្រព័ន្ធអនុគ្រោះ |

| | |
|---|---|
| ដើម្បីទទួលបានសេវា | ពាណិជ្ជកម្ម<br>- ពាក្យស្នើសុំចុះបញ្ជី<br>- លិខិតបញ្ជាក់ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ច្បាប់ដើមឬថតចម្លង ប្រថាប់ត្រាខេត្ត-ក្រុង)<br>- លិខិតអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ច្បាប់ដើមឬថតចម្លង ប្រថាប់ត្រាខេត្ត -ក្រុង)<br>- លក្ខន្តិកៈបើកក្រុមហ៊ុន និងគម្រោងរបាយការណ៍សេដ្ឋកិច្ច (លក្ខន្តិកៈ-ច្បាប់ដើមឬថត ចម្លងប្រថាប់ត្រាខេត្ត-ក្រុង)<br>- ប្រកាសអនុញ្ញាតពីឧស្សាហកម្ម (ច្បាប់ដើម ឬថតចម្លងប្រថាប់ត្រាខេត្ត ក្រុង)<br>- វិញ្ញាបនបត្រចូលសមាគមរោងចក្រកាត់ដេរកម្ពុជា និង ILO(សម្រាប់រោងចក្រកាត់ដេរ)<br>- លិខិតជួលទីតាំងប័ណ្ណកម្មសិទ្ធិចំពោះជនជាតិខ្មែរ (ច្បាប់ដើម ឬថតចម្លង ប្រថាប់ត្រាខេត្ត ក្រុង)<br>- លិខិតអនុញ្ញាតសាងសង់<br>- ប្លង់សាងសង់រោងចក្រ<br>- លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណចំពោះជនជាតិខ្មែរ<br>និងរូបថត............០១សន្លឹក<br>- លិខិតប្រគល់សិទ្ធិពីប្រធានក្រុមហ៊ុនឱ្យអ្នកជំនួស (អ្នកជំនួសត្រូវមានលិខិតឆ្លងដែន<br>ឬអត្តសញ្ញាណប័ណ្ណចំពោះជនជាតិខ្មែរ<br>រូបថត..................................០១សន្លឹក)<br>- រូបថតអគាររោងចក្រ..................................................................០២សន្លឹក<br>- រូបថតសង្វាក់ផលិតកម្ម ០២សន្លឹក និង រូបថតផលិតផល...................០២សន្លឹក<br>២-ចំពោះការចុះបញ្ជីសុំសិទ្ធិនាំចេញក្រោមគម្រោងអនុគ្រោះពន្ធសម្រាប់សហគ្រាសសិប្បកម្មតម្រូវឱ្យមានឯកសារភ្ជាប់ដូចខាងក្រោម :<br>- លិខិតបញ្ជាក់របស់ក្រសួងពាក់ព័ន្ធ<br>- លិខិតបញ្ជាក់ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម<br>- លក្ខន្តិកៈបើកក្រុមហ៊ុន<br>- ប៉ាតង់<br>- លិខិតជួលទីតាំង-ស្នាក់ការ |

| | |
|---|---|
| | - លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ<br>- រូបថតស្លាកការ និងផលិតផល<br>៣-ការស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញសម្រាប់ដឹកជញ្ជូនតាមមធ្យោបាយផ្លូវទឹក និងផ្លូវអាកាសត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួនដូចខាងក្រោម:<br>• ពាក្យស្នើសុំវិញ្ញាបនបត្រប្រភពដើមទំនិញ<br>• កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញនាំចេញរបស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ ទំនិញនាំចេញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ និងទីចាត់ការគយ និង រដ្ឋាករ ។<br>• អញ្ញាត្តិប័ណ្ណដឹកជញ្ជូនតាមផ្លូវទឹក (Bill of Lading) ឬអញ្ញាត្តិប័ណ្ណដឹកជញ្ជូនតាមអាកាស (Airway Bill) ចំពោះការដឹកជញ្ជូនតាមផ្លូវអាកាស (By Air)<br>• ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)<br>• វិក្កយបត្រ (Invoice)<br>• តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)<br>• កិច្ចសន្យាទិញលក់ (Sale Contract)<br>• មូលប្បទានប័ត្រសម្រាប់សោហ៊ុយរដ្ឋបាល និងកម្រៃសម្រាប់គ្រប់គ្រងការនាំចេញ |
| យោបល់ | - ផ្តល់សេវាចុះបញ្ជីនេះដើម្បីជូនសហគ្រាស និងក្រុមហ៊ុនពាណិជ្ជកម្មក្នុងគោលបំណង ពង្រឹងនូវការគោរពរាល់វិធានប្រភពដើមនៃបណ្តាប្រទេសដែលផ្តល់ភាព អនុគ្រោះពាណិជ្ជកម្មចំពោះកម្ពុជាលើសពីនោះក៏បានចូលរួមចាប់បង្ខំឱ្យសហគ្រាស និងក្រុមហ៊ុនខាងលើចាប់អារម្មណ៍ខ្ពស់ពីការទទួលខុសត្រូវចំពោះសង្គម(សិទ្ធិកម្មករ) ដោយ មានកិច្ចសហប្រតិបត្តិការជាមួយអង្គការពលកម្មអន្តរជាតិ (ILO) ។<br>- ការអនុវត្តគោលនយោបាយកិច្ចសម្រួលពាណិជ្ជកម្មបានជះឥទ្ធិពលអវិជ្ជមានខ្លះការ ប្រមូលកម្រៃជូនថវិការដ្ឋដោយមូលហេតុថាគោលនយោបាយបានសម្រួលឱ្យអ្នក នាំចេញកម្ពុជាធ្វើការនាំចេញរួចហើយទើបមកសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើម ជាក្រោយ ។ នៅពេលស្នើសុំវិញ្ញាបនបត្រ ទើបកម្រៃខាងលើចាប់តម្រូវឱ្យអ្នកនាំចេញបង់ជូនរដ្ឋ ។ កន្លងមករោងចក្រខ្លះបានចេញទំនិញរួចហើយមិនបានមកបំពេញកាតព្វកិច្ចបង់កម្រៃឡើយ ហើយត្រូវបិទទ្វារឈប់ដំណើរការ ឬត្រូវក្ស័យធន |

| | |
|---|---|
| | តែម្តងដែលធ្វើឱ្យចំណូលរដ្ឋត្រូវបាត់បង់ ។ |

# វិញ្ញាបនបត្រប្រភពដើមទំនិញ ដើម្បីនាំទំនិញទៅទ្វីបអាស៊ី និង អូសេអានី

| | |
|---|---|
| ឈ្មោះសេវា | វិញ្ញាបនបត្រប្រភពដើមទំនិញ ដើម្បីនាំទំនិញទៅទ្វីបអាស៊ី និង អូសេអានី |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងពាណិជ្ជកម្ម<br>នាយកដ្ឋានពាណិជ្ជកម្មពហុភាគី<br>ឡូតិ៍លេខ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម(ផ្លូវលេខ១១៣បេ)សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០១២ ៦២៩ ៦២៨ , ០៩៧ ៩៣៦ ៨៨៨៨<br>ទូរសារ : ០២៣ ៨៦៦ ០៩៨<br>អ៊ីម៉ែល : sanphirunna@yahoo.com , oungsokhan676456@yahoo.com |
| គោលបំណង នៃការផ្តល់សេវា | បញ្ជាក់ពីប្រភពដើមទំនិញដែលផលិតនៅប្រទេសកម្ពុជា |
| មូលដ្ឋានគតិយុត្ត | - ប្រកាសលេខ ០១៤ ព.ណ បអពប្រក ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការចេញវិញ្ញាបនបត្រប្រភពដើមទំនិញកម្ពុជាចំពោះទំនិញសំលៀកបំពាក់សម្រាប់នាំចេញរបស់ក្រសួងពាណិជ្ជកម្ម ។<br>- ប្រកាសលេខ ៥១៥ ព.ណ បអព ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការកំណត់នីតិវិធីថ្មីសម្រាប់ដាក់ពាក្យសុំវិញ្ញាបនបត្រប្រភពដើម លិខិតអនុញ្ញាតនាំចេញបណ្តោះអាសន្ន និងទិដ្ឋាការនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ។<br>- ប្រកាសលេខ ១៦៩៥ ព.ណ បអព ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២000 ស្តីពីការកំណត់កម្រៃវិញ្ញាបនបត្រប្រភពដើមទំនិញនាំចេញរបស់ក្រសួងពាណិជ្ជកម្ម<br>- ប្រកាសលេខ ២៦៥ MoC / M ២០០២ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញជូនអង្គការក្រៅរដ្ឋាភិបាល(NGOs) របស់ក្រសួងពាណិជ្ជកម្ម ។<br>- ប្រកាសលេខ ០២១ MOC/M ២០០៤ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ជូនសិប្បកម្មក្នុងស្រុករបស់ក្រសួងពាណិជ្ជកម្ម ។<br>- ប្រកាសលេខ ១៥៩ MOC / M ២០០៤ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ, វិក្កយបត្រពាណិជ្ជកម្ម,អាជ្ញា ប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ។<br>- ប្រកាសលេខ 186 ព.ណ បអពប្រក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤ |

| | |
|---|---|
| | ស្តីពីការ កែសម្រួលនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ, វិក្កយបត្រ ពាណិជ្ជ កម្ម។ អាជ្ញាប័ណ្ណនាំចេញតាមជើងយន្តហោះរបស់ក្រសួងពាណិជ្ជកម្ម<br>- ប្រកាសលេខ 070 MOC / M 2005 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ, វិក្កយបត្រពាណិជ្ជ កម្ម, អាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម។<br>- ប្រកាសលេខ 261 MOC / M 2005 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ, វិក្កយបត្រ ពាណិជ្ជ-កម្ម, អាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម។<br>- ប្រកាសលេខ 104 MOC / M 2005 ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ វិក្កយបត្រពាណិជ្ជកម្មតាមជើងយន្តហោះទៅសហរដ្ឋអាមេរិករបស់ក្រសួងពាណិជ្ជកម្ម។<br>- ប្រកាសលេខ 273 ព.ណ បអពប្រក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រសួងពាណិជ្ជកម្ម<br>- ប្រកាសលេខ 285 ព.ណ បអពប្រក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការកំណត់កម្រៃ គ្រប់គ្រងការនាំចេញរបស់ក្រសួងពាណិជ្ជកម្ម។<br>- ប្រកាសលេខ 193 MOC/SM 2006 ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការបង់កម្រៃគ្រប់គ្រងការនាំចេញសម្រាប់សំលៀកបំពាក់អនាម័យដែលប្រើតែមួយលើករួចហើយបោះចោលរបស់ក្រសួងពាណិជ្ជកម្ម។<br>- ប្រកាសលេខ 176 MOC/SM 2006 ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦ ស្តីពីវិធានការចាំបាច់មួយចំនួនសម្រាប់គ្រប់គ្រងការនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម។<br>- ប្រកាសលេខ 232 MOC/SM 2006 ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការពិន័យចំពោះការយឺតយូរមិនព្រមបង់កំរៃគ្រប់គ្រងការនាំចេញរបស់ក្រសួងពាណិជ្ជកម្ម។<br>- ប្រកាសអន្តរក្រសួងលេខ 044 MOC/SM 2007 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលការកំណត់កម្រៃគ្រប់គ្រងការនាំចេញ និងសោហ៊ុយពាក់ព័ន្ធរបស់ក្រសួងពាណិជ្ជកម្ម។<br>- ប្រកាសអន្តរក្រសួងលេខ 097 MOC/SM 2007 ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួល និងការកំណត់កម្រៃគ្រប់គ្រងការនាំចេញរបស់ក្រសួងពាណិជ្ជ កម្ម។ |

| | |
|---|---|
| | - ប្រកាសលេខ 045 MOC/SM 2008 ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការនាំចេញសំលៀកបំពាក់ពណិប៉ារ៉ា ពណិបៃតង ( ត្រីអ៊ី ) និងកាតីរបស់ក្រសួងពាណិជ្ជកម្ម ។<br>- ប្រកាសលេខ 106 MOC / SM 2008 ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០៨ ស្តីពីការផ្តល់វិញ្ញាបនបត្រប្រភពដើមទំនិញតាមជើងយន្តហោះ បន្ទាប់ពីដឹកជញ្ជូនតាម រថយន្តឆ្លងកាត់ព្រំដែនកម្ពុជារបស់ក្រសួងពាណិជ្ជកម្ម ។<br>- ប្រកាសលេខ 110 MOC/SM 2007 ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០០៨ ស្តីពីការចុះបញ្ជីសុំសិទ្ធិនាំចេញក្រោមគំរោងអនុគ្រោះពន្ធសម្រាប់សហគ្រាសសិប្បកម្មរបស់ក្រសួងពាណិជ្ជកម្ម ។ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | នីតិបុគ្គល |
| ស្តង់ដារសេវា | រយៈពេលនៃការផ្តល់វិញ្ញាបនបត្រប្រភពដើមទំនិញគឺ ១០ម៉ោង និង ៥៥នាទី |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ការស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញសម្រាប់ដឹកជញ្ជូនតាមមធ្យោបាយផ្លូវ ទឹក និងផ្លូវអាកាសត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួនដូចខាងក្រោម :<br>- ពាក្យស្នើសុំវិញ្ញាបនបត្រប្រភពដើមទំនិញ<br>- កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញនាំចេញរបស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនាំចេញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ និងទីចាត់ការគយ និងរដ្ឋាករ ។<br>- អញ្ញត្តិប័ណ្ណដឹកជញ្ជូនតាមផ្លូវទឹក (Bill of Lading) ឬអញ្ញត្តិប័ណ្ណដឹកជញ្ជូន តាមអាកាស (Airway Bill) ចំពោះការដឹកជញ្ជូនតាមផ្លូវអាកាស (By Air)<br>- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)<br>- វិក្កយបត្រ (Invoice)<br>- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)<br>- មូលប្បទានប័ត្រសម្រាប់សោហ៊ុយរដ្ឋបាល និងកម្រៃសម្រាប់គ្រប់គ្រងការនាំចេញ |
| យោបល់ | -គ្រប់បណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាសទាំងអស់ត្រូវមកចុះបញ្ជីជាមុន ដើម្បីទទួលសិទ្ធិក្នុងការស្នើសុំវិញ្ញាបនបត្រប្រភពដើមគ្រប់ប្រភេទពីនាយកដ្ឋានពាណិជ្ជកម្មពហុភាគី ។<br>* ឯកសារមូលដ្ឋានសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីរួមមាន : |

| | |
|---|---|
| | ក-<br>ពាក្យស្នើសុំចុះបញ្ជីក្រុមហ៊ុននៅនាយកដ្ឋានពាណិជ្ជកម្មពហុភាគី.....(មួយច្បាប់)<br>ខ-<br>លិខិតបញ្ជាក់ចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្មច្បាប់ថតចម្លងមួយច្បាប់<br>គ- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម ច្បាប់ថតចម្លង<br>...........(មួយច្បាប់)<br>ឃ- ប័ណ្ណប៉ាតង់ច្បាប់ថតចម្លង<br>.......................................................(មួយច្បាប់)<br>ង- វិញ្ញាបនបត្រចុះបញ្ជីអាករលើតំលៃបន្ថែម ច្បាប់ថតចម្លង<br>............(មួយច្បាប់)<br>ច- លក្ខន្តិកៈក្រុមហ៊ុន ច្បាប់ថតចម្លង<br>............................................(មួយច្បាប់)<br>ឆ- លិខិតសម្គាល់ខ្លួន (Passport) ច្បាប់ថតចម្លង<br>...........................(មួយច្បាប់)<br>ជ- រូបថត 4x6 = ២សន្លឹក<br>- គ្រប់បណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាសទាំងអស់ត្រូវដាក់ពាក្យស្នើសុំ វិញ្ញាបនបត្រ តាមការតម្រូវរបស់ប្រទេសនាំចូល ឬដើម្បីឱ្យទំនិញនាំចេញទាំងនោះបានទទួលភាពអនុគ្រោះពាណិជ្ជកម្មនៅក្នុងប្រទេសនាំចូល។ |

# វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញនាំចេញទៅកាន់ទ្វីបអឺរ៉ុប ទ្វីបអាហ្វ្រិក និង អាជ្ញាប័ណ្ណនាំចេញ នាំចូលទំនិញ

| | |
|---|---|
| ឈ្មោះសេវា | ១-វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញនាំចេញទៅកាន់ទ្វីបអឺរ៉ុប ទ្វីបអាហ្វ្រិក<br>២-អាជ្ញាប័ណ្ណនាំចេញ នាំចូលទំនិញ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងពាណិជ្ជកម្ម<br>នាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី<br>ឡូត៍លេខ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម(ផ្លូវលេខ១១៣បេ)សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>លេខទូរស័ព្ទ : ០២៣ ៨៦៦ ០៥៦<br>អ៊ីម៉ែល : FTD4444@yahoo.com.kh |
| គោលបំណង នៃការផ្តល់សេវា | - បញ្ជាក់ពីប្រភពដើមទំនិញដែលផលិតនៅប្រទេសកម្ពុជា។<br>- គ្រប់គ្រងទំនិញនាំចេញ នាំចូលតាមច្បាប់ និងបទបញ្ញត្តិដែលកំណត់ដោយរាជរដ្ឋាភិបាល។ |
| មូលដ្ឋានគតិយុត្ត | - ច្បាប់ព្រៃឈើ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២<br>- អនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីយថាប្រភេទផលអនុផលព្រៃឈើអនុញ្ញាតឱ្យនាំចេញ នាំចូល។<br>- អនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់។<br>- ប្រកាសលេខ ១៥៩ MOC/M ២០០៤ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ វិក្កយបត្រពាណិជ្ជកម្មអាជ្ញាប័ណ្ណនាំចេញ។<br>- ប្រកាសអន្តរក្រសួងលេខ ០៤៤ MOC/SM២០០៧ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលការកំណត់កំរៃគ្រប់គ្រងការនាំចេញ និងសោហ៊ុយរដ្ឋបាលពាក់ព័ន្ធ។<br>- ប្រកាសអន្តរក្រសួងលេខ ០៩៧ MOC/SM ២០០៧ ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលការកំណត់ថ្មីកម្រៃគ្រប់គ្រងការនាំចេញ។<br>- លិខិតជូនដំណឹងលេខ 0176 MOC/SM2008 ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៨ របស់ក្រសួងពាណិជ្ជកម្ម។ |

| | |
|---|---|
| អតិថិជនដែលមានសិទ្ធិទទួលសេវា | រូបវន្តបុគ្គល ឬ នីតិបុគ្គល |
| ស្តង់ដារសេវា | ⇨ ចំពោះវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញប្រើប្រាស់រយៈពេល ៧ម៉ោង ៣៧ នាទី ( ម៉ោងធ្វើការ )" ចាប់ពីដាក់ពាក្យសុំនៅនាយកដ្ឋានរហូតដល់ការប្រគល់ឯកសារ" ។ បើតាមប្រកាសរបស់ក្រសួងលេខ ១៥៩ MOC/M ២០០៤ ចុះថ្ងៃទី១៩ ខែ សីហា ឆ្នាំ ២០០៤ មានរយៈពេលប្រើប្រាស់រហូតដល់ ១១ម៉ោង ៥៥ នាទី (ម៉ោងធ្វើការ) ។<br>⇨ ចំពោះអាជ្ញាប័ណ្ណនាំចេញ-នាំចូលទំនិញប្រើប្រាស់រយៈពេល ២ ម៉ោង (ម៉ោងធ្វើការ) ។ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ✡ ចំពោះការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញត្រូវមានឯកសារ :<br>**✪ នាំចេញតាមផ្លូវទឹក :**<br>- លិខិតស្នើសុំរបស់អ្នកនាំចេញ<br>- កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញនាំចេញរបស់អគ្គនាយកដ្ឋានកម្ពុជាត្រួត ពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល" និង ទីចាត់ការគយ និងរដ្ឋាករ ។<br>- អញ្ញត្តិប័ណ្ណដឹកជញ្ជូន ( Bill of Lading )<br>- វិក្កយបត្រ (Invoice)<br>- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)<br>- កិច្ចសន្យាទិញលក់ (Sale Contract)<br>- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)<br>- មូលប្បទានប័ត្រសម្រាប់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងនាំចេញ<br>**✪ នាំចេញតាមផ្លូវអាកាស :**<br>- លិខិតស្នើសុំរបស់អ្នកនាំចេញ<br>- វិក្កយបត្រ (Invoice)<br>- តារាងបញ្ជាក់ការវេចខ្ចប់ ( Packing List )<br>- កិច្ចសន្យាទិញ-លក់ (Sale Contract)<br>- មូលប្បទានប័ត្រសម្រាប់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងនាំចេញ នៅពេលទំនិញចេញរួចត្រូវភ្ជាប់ឯកសារបន្ថែមដូចខាងក្រោម :<br>- កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញនាំចេញរបស់អគ្គនាយកដ្ឋានកម្ពុជាត្រួត ពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល" |

| | |
|---|---|
| | និងទីចាត់ ការគយ និងរដ្ឋាករ ។<br>- អញ្ញាត្តិប័ណ្ណដឹកជញ្ជូនតាមផ្លូវអាកាស ( Airway Bill )<br>- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)<br>✡ ចំពោះការចេញអាជ្ញាប័ណ្ណនាំចេញ-នាំចូលទំនិញត្រូវមានឯកសារ<br>**១-ផល-អនុផលព្រៃឈើ:**<br>- លិខិតអនុញ្ញាតជាគោលការណ៍របស់រាជរដ្ឋាភិបាល<br>- លិខិតស្នើសុំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូសមុខឱ្យក្រុមហ៊ុន ធ្វើអាជីវកម្មនាំចេញ-នាំចូល ផលអនុផលព្រៃឈើមកក្រសួងពាណិជ្ជកម្ម ។<br>- ពាក្យស្នើសុំអាជ្ញាប័ណ្ណនាំចេញ-នាំចូលរបស់ក្រុមហ៊ុន ។<br>- កិច្ចសន្យាទិញ-លក់ ។<br>- អាជ្ញាប័ណ្ណនាំចេញ-នាំចូលត្រូវផ្តល់ដោយក្រសួងពាណិជ្ជកម្ម និងមានចុះ ទិដ្ឋាការជាមុនដោយប្រធានរដ្ឋបាលព្រៃឈើ ។<br>**២-ផលិតផលឈើដើមកៅស៊ូកែច្នៃ :**<br>- លិខិតអនុញ្ញាតជាគោលការណ៍របស់រាជរដ្ឋាភិបាល<br>- លិខិតស្នើសុំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជូសមុខឱ្យក្រុមហ៊ុន ធ្វើអាជីវកម្មនាំចេញ-នាំចូល ផល អនុផលព្រៃឈើមកក្រសួងពាណិជ្ជកម្ម ។<br>- ពាក្យស្នើសុំអាជ្ញាប័ណ្ណនាំចេញ-នាំចូលរបស់ក្រុមហ៊ុន<br>- កិច្ចសន្យាទិញ-លក់<br>- អាជ្ញាប័ណ្ណនាំចេញ-នាំចូលត្រូវផ្តល់ដោយក្រសួងពាណិជ្ជកម្ម និងមានចុះទិដ្ឋាការ ដោយប្រធានក្រុមហ៊ុនផ្ទាល់ ។<br>**៣-បញ្ជីទំនិញហាមឃាត់ និង ទំនិញដាប់កម្រិតកំណត់** ក្រៅពីផល-អនុផលព្រៃឈើ និងផលិតផលឈើកៅស៊ូកែច្នៃដែលតម្រូវឱ្យមានអាជ្ញាប័ណ្ណ នាំចេញ-នាំចូល និងលិខិតអនុញ្ញាត ពីក្រសួងពាណិជ្ជកម្មដោយយោងតាមឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៧ ។ |
| យោបល់ | ១-អ្នកនាំចេញត្រូវតែស៊ីវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ព្រោះជួយឱ្យអ្នកនាំ ចេញទទួលបានផលប្រយោជន៍ :<br>- បញ្ជាក់ពីប្រភពដើមទំនិញដែលផលិតនៅប្រទេសកម្ពុជា<br>- ទទួលបានភាពអនុគ្រោះពន្ធពីប្រទេសនាំចូល ។<br>២-<br>រាល់មុខទំនិញសំខាន់ៗដែលស្ថិតក្នុងការហាមឃាត់និងការការពារពីរាជរដ្ឋាភិបា |

| | |
|---|---|
| | ល ការនាំចេញ នាំចូលត្រូវតែមានការអនុញ្ញាតពីក្រសួងពាណិជ្ជកម្មតាមរយៈអាជ្ញាប័ណ្ណនាំចេញ-នាំចូលទំនិញដើម្បីឱ្យស្របតាមច្បាប់ និងបទបញ្ញត្តិ ។ |

# សេវាពាក់ព័ន្ធនឹង

**១. សេវាត្រួតពិនិត្យទំនិញនាំចេញ-នាំចូល រួមជាមួយស្ថាប័នគយ និងរដ្ឋាករ ផ្អែកលើកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ**

**២. វិញ្ញាបនបត្រកម្មចំពោះទំនិញនាំចេញតាមសំណើរបស់អ្នកស្នើសុំដើម្បីបំពេញលក្ខខណ្ឌតម្រូវតាមប្រទេសនាំចូល**

**៣. ផ្តល់សេវាការពារដល់អ្នកប្រើប្រាស់តាមការឃ្លាំពិនិត្យទីផ្សារ និង ការបង្ក្រាបការក្លែងបន្លំ**

| | |
|---|---|
| ឈ្មោះសេវា | - សេវាត្រួតពិនិត្យទំនិញនាំចេញ-នាំចូលរួមជាមួយស្ថាប័នគយ និងរដ្ឋាករផ្អែកលើកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ<br>- វិញ្ញាបនបត្រកម្មចំពោះទំនិញនាំចេញតាមសំណើរបស់អ្នកស្នើសុំ ដើម្បីបំពេញលក្ខខណ្ឌតម្រូវតាមប្រទេសនាំចូល<br>- ផ្តល់សេវាការពារដល់អ្នកប្រើប្រាស់តាមការឃ្លាំពិនិត្យទីផ្សារ និងការបង្ក្រាបការក្លែងបន្លំ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងពាណិជ្ជកម្ម<br>អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ<br>លេខ ៥០E₀ ផ្លូវ ១៤៤ សង្កាត់ផ្សារកណ្តាល១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរស័ព្ទ/ទូរសារ : ៨៥៥-២៣-៤២៦ ១៦៦<br>អ៊ីម៉ែល : cpd@camnet.com |
| គោលបំណង<br>នៃការផ្តល់សេវា | - ធានាគុណភាព សុវត្ថិភាពផលិតផល (ម្ហូបអាហារ និងមិនមែនម្ហូបអាហារ) និងសេវា និង ការពារអ្នកប្រើប្រាស់ ។<br>- ធានាកិច្ចការពារពាណិជ្ជកម្មប្រកបដោយសមធម៌ ។<br>- ធានាអនុលោមភាពនៃបណ្តាលក្ខខណ្ឌតម្រូវផ្អែកច្បាប់ពាក់ព័ន្ធនឹងពាណិជ្ជកម្ម ។<br>- ទទួលផ្តល់សេវាត្រួតពិនិត្យពាណិជ្ជកម្មជាលក្ខណៈភាគីទី៣ ។<br>- ជំរុញឱ្យផលិតផលម្ហូបអាហារ ផលិតផលមិនមែនម្ហូបអាហារលក់លើទីផ្សារមានគុណភាព សុវត្ថិភាព ការពារផលប្រយោជន៍អ្នកប្រើប្រាស់ ។<br>- ផ្តល់សេវាការពារដល់អ្នកប្រើប្រាស់តាមការឃ្លាំពិនិត្យទីផ្សារ និងការបង្ក្រាបការក្លែងបន្លំ ។ |
| មូលដ្ឋានគតិយុត្ត | - ព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០០ ស្តីពីការដាក់ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព |

| | |
|---|---|
| | សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា<br>- អនុក្រឹត្យលេខ ៥៩អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឱ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)<br>- សារាចរណែនាំអន្តរក្រសួងលេខ ២៥៦ ពណផកសរណេន ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីសោហ៊ុយត្រួតពិនិត្យទំនិញនាំចេញ-នាំចូលរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ប្រកាសអន្តរក្រសួង លេខ ០១ ប្រក.កយ ពណ ២០០៤ ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូសំណុំលិខិតដោះស្រាយបទល្មើសស្តីពី គុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវាដល់មន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងពាណិជ្ជកម្ម<br>- ប្រកាសលេខ ០០៧ MoC/M 2004 ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ២០០៤ ស្តីពីវិធានការហាមឃាត់ការនាំចូលជាបណ្តោះអាសន្ននូវបក្សី ស៊ុតបក្សី សាច់បក្សីស្រស់ និងក្លាស្សេ និងផលិតផលមានដើមកំណើតពីបក្សី<br>- ប្រកាសអន្តរក្រសួងលេខ ៩៩៤ សហរ.ប្រក ចុះថ្ងៃ ០៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | គ្រប់ការីសេដ្ឋកិច្ចពាក់ព័ន្ធការធ្វើពាណិជ្ជកម្ម ជាអាទិ៍ ការនាំចេញ នាំចូល ការផលិតកែច្នៃ ការស្តុកទុក និង ការលក់ចែកចាយទំនិញ និងអ្នកប្រើប្រាស់ទូទៅ។ |
| ស្តង់ដារសេវា | • ស្តង់ដារពេលវេលារបស់អគ្គនាយកដ្ឋានកាំកុងត្រូលក្នុងការបំពេញនីតិវិធីសម្រេចបាននូវការបញ្ចេញទំនិញ ពី០៨ ដល់ ១៦ម៉ោង<br>• កម្រៃសេវាត្រួតពិនិត្យទំនិញ គឺ 0.១% នៃតម្លៃ CIF សម្រាប់ទំនិញជាវត្ថុស្ងួត ឬ អនុលោមទៅតាមទំហំនៃការងារ<br>• កម្រៃសេវាត្រួតពិនិត្យទំនិញគឺ 0.0៣% នៃតម្លៃ CIF សម្រាប់ទំនិញជាវត្ថុរាវ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | សំណើពិនិត្យលក្ខណៈសម្បត្តិសម្រាប់នាំចេញ នាំចូល តាមការផ្តល់ដំណឹងនៃការនាំចេញ នាំចូលជាក់ស្តែង (ពាក្យស្នើសុំ) ក្នុងក្របខ័ណ្ឌនៃការអនុវត្តវិធីសាស្ត្រគ្រប់គ្រង ហានិភ័យដោយមានឯកសារគាំទ្រ :<br>• អាញ្ញត្តិប័ត្រ (B/L)<br>• វិក្កយបត្រ និង បញ្ជីវេចខ្ចប់ (Invoice and Packing List) |

| | |
|---|---|
| | • ឯកសារពាក់ព័ន្ធ និង កិច្ចធានាគុណភាព សុវត្ថិភាព ទិសដៅប្រើប្រាស់ (ជាក់ស្តែង តាមប្រភេទទំនិញ) តាមការចាំបាច់ ។ |
| យោបល់ | • ការផ្តល់សេវានេះ ជាបទដ្ឋានគតិយុត្តសំខាន់បំផុតសម្រាប់ឈានទៅការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវាក្នុងទិសដៅធានាឱ្យបាននូវផលប្រយោជន៍របស់អតិថិជនក្នុងការធ្វើពាណិជ្ជកម្មដោយស្មោះត្រង់ និងយុត្តិធម៌ ផ្អែកលើកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ។<br>• សេវានេះ (លើកលែងតែការត្រួតពិនិត្យពាណិជ្ជកម្ម ជាលក្ខណៈភាគីទី៣) មានលក្ខណៈជាច្បាប់ ។<br>• ចំពោះការត្រួតពិនិត្យពាណិជ្ជកម្មលក្ខណៈជាភាគីទី៣ អង្គភាពត្រួតពិនិត្យពាណិជ្ជកម្មនៃអគ្គនាយកដ្ឋានមានទំនុកចិត្តពីអតិថិជនបរទេសជាច្រើន។ ការប្រើប្រាស់សេវានេះនឹងមានលក្ខណៈពិតប្រាកដក្នុងកិច្ចធានាការបំពេញបំណងរបស់អតិថិជន។ |

## សេវាដែលពាក់ព័ន្ធនឹង

**១-សម្របសម្រួលកិច្ចការពិព័រណ៍**

**២-តម្កល់លក្ខន្តិកៈសមាគម**

**៣-ផ្តល់វិញ្ញាបនបត្រគ្រប់គ្រងអាជីវកម្ម**

**៤-សេវាកម្ម និង ពាណិជ្ជកម្ម**

**៥-ផ្តល់លិខិតអនុញ្ញាតឱ្យអាជីវករបិទស្លាកថ្លៃជារូបិយវត្ថុបរទេស**

**៦-ផ្តល់ទីប្រឹក្សាពិគ្រោះយោបល់លើកិច្ចការពាណិជ្ជកម្ម**

**៧-ផ្តល់លិខិតអនុញ្ញាតិប្រកបអាជីវកម្មត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ**

| | |
|---|---|
| ឈ្មោះសេវា | - សម្របសម្រួលកិច្ចការពិព័រណ៍<br>- តម្កល់លក្ខន្តិកៈសមាគម<br>- ផ្តល់វិញ្ញាបនបត្រគ្រប់គ្រងអាជីវកម្ម<br>- សេវាកម្ម និងពាណិជ្ជកម្ម<br>- ផ្តល់លិខិតអនុញ្ញាតឱ្យអាជីវករបិតស្លាកថ្លៃជារូបិយវត្ថុបរទេស<br>- ផ្តល់ទីប្រឹក្សាពិគ្រោះយោបល់លើកិច្ចការពាណិជ្ជកម្ម<br>- ផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្មត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងពាណិជ្ជកម្ម<br>នាយកដ្ឋានជំរុញពាណិជ្ជកម្ម<br>លេខ ៦៥-៦៩ ផ្លូវ ១៣៦ សង្កាត់ផ្សារកណ្តាល១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ២១ ៧៣ ៥៣<br>ទូរសារ : ០២៣ ២១ ១៧ ៤៥<br>គេហទំព័រ : www.tpd.gov.kh |
| គោលបំណង<br>នៃការផ្តល់សេវា | ជំរុញសកម្មភាពពាណិជ្ជកម្មឱ្យមានភាពទូលំទូលាយទូទាំងប្រទេសនិងបង្កើនសកម្មភាព នាំចេញ រួមទាំងគ្រប់គ្រងស្ថេរភាពតម្លៃទីផ្សារ។ |
| មូលដ្ឋានគតិយុត្ត | - ព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើនូវច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម។<br>- ព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពី |

| | |
|---|---|
| | ការប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។<br>- ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៥ ស្តីពីការប្រកាសឱ្យប្រើនូវច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។<br>- ប្រកាសលេខ ២៦៧ ពណ.កបទប្រក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការតម្កល់ទុកលក្ខន្តិកៈសមាគមអាជីវកម្មរបស់ក្រសួងពាណិជ្ជកម្ម។<br>- ប្រកាសលេខ ១២៥ MOC/ SM ២០០៨ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទរបស់ក្រសួងពាណិជ្ជកម្ម ។<br>- ប្រកាសលេខ ១២៣ MOC/SM ២០០៨ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការគ្រប់គ្រងសកម្មភាពអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម។<br>- ប្រកាសលេខ ២២៨ MOC/SM 2009 ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្មលោហធាតុត្បូងថ្មមានតំលៃជាគ្រឿងអលង្ការ។ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | ពាណិជ្ជករទូទៅទទួលបានសិទ្ធិដូចៗគ្នា។ |
| ស្តង់ដារសេវា | សេវារហ័សមិនអូសបន្លាយពេលវេលា<br>សកម្មភាពយ៉ាងយកចិត្តទុកដាក់របស់មន្ត្រី ជំនាញ (មានរយៈពេល ៧ថ្ងៃ) |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ពាក្យស្នើសុំរបស់ក្រុមហ៊ុន ឬ របស់ពាណិជ្ជករ |
| យោបល់ | - ពាណិជ្ជករ អាជីវករ ផលិតករ គួរចូលរួមការតាំងពិព័រណ៍ទាំងក្នុង និងក្រៅប្រទេស ឱ្យបានច្រើនដើម្បីស្វែងរកទីផ្សារសម្រាប់ផលិតផលរបស់ខ្លួន និងស្វែងយល់អំពី តម្រូវការរបស់ទីផ្សារ ថាតើគេត្រូវការផលិតផលអ្វីខ្លះ ដើម្បីឱ្យយើងងាយស្រួល ក្នុងការអភិវឌ្ឍផលិតផលរបស់ខ្លួនឱ្យត្រូវតាមតម្រូវការទីផ្សាររបស់គេ។<br>- តម្កល់ទុកឯកសារលក្ខន្តិកៈរបស់សមាគមអាជីវកម្មនានា ដើម្បីលើកទឹកចិត្តឱ្យ សមាគមធ្វើសកម្មភាពប្រកបដោយនិរន្តភាព ព្រមទាំងបង្កឱ្យមានលក្ខណៈងាយ ស្រួលក្នុងការទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ បណ្តាសមាគមអាជីវកម្មក្នុងស្រុក និងសមាគមអាជីវកម្មនៅលើពិភពលោក។<br>- មកសុំវិញ្ញាបនបត្រគ្រប់គ្រងអាជីវកម្ម ដើម្បីធានាបាននូវភាពស្របច្បាប់របស់អាជីវករ។<br>- ការបិទស្លាកថ្លៃលើទំនិញ គឺដើម្បីអភិវឌ្ឍសេដ្ឋកិច្ចទីផ្សារសេរី ប្រកួតប្រជែងដោយសមធម៌ ពិសេសគឺដើម្បីបម្រើដល់ប្រយោជន៍អ្នកប្រើប្រាស់ |

| | |
|---|---|
| | - មកពិគ្រោះយោបល់ផ្នែកពាណិជ្ជកម្មដើម្បីទទួលបាននូវព័ត៌មានសំខាន់ៗ សម្រាប់ជា មូលដ្ឋានក្នុងការធ្វើពាណិជ្ជកម្ម ដើម្បីឱ្យមានភាពងាយស្រួលក្នុងការធ្វើពាណិជ្ជកម្ម និងទទួលបានជោគជ័យក្នុងការធ្វើជំនួញ និងការវិនិយោគរបស់ខ្លួន។<br>- មកស៊ីវិញ្ញាបនប័ត្រគ្រប់គ្រង អាជីវកម្មលោហធាតុ ត្បូងថ្មមានតំលៃជា គ្រឿងអលង្ការ គឺដើម្បីទទួលបានភាពស្របច្បាប់ និងការពារនូវការក្លែងបន្លំ ភូតភរ រំលោភសេចក្ដីទុកចិត្ត ឬឆបោកអតិថិជន។ |

# ការតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា

| | |
|---|---|
| ឈ្មោះសេវា | ការតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា |
| ក្រសួង/ស្ថាប័នផ្ដល់សេវា | ក្រសួងពាណិជ្ជកម្ម<br>នាយកដ្ឋាននីតិកម្ម<br>ឡូត៍លេខ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម(ផ្លូវលេខ១១៣បេ) សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>គេហទំព័រ : www.setfo.gov.kh<br>អ៊ីម៉ែល: www.setfo.moc@gmail.com |
| គោលបំណង<br>នៃការផ្ដល់សេវា | - ការប្រើប្រាស់ចលនវត្ថុជាទ្រព្យធានា<br>- បង្កើនឥណទានហិរញ្ញវត្ថុតាមរយៈការប្រើប្រាស់ចលនវត្ថុជាទ្រព្យធានា |
| មូលដ្ឋានគតិយុត្ត | - ព្រះរាជក្រមលេខ នស/រកម/០៥០៧/០១២ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៧ ស្ដីពីការប្រកាសឱ្យប្រើនូវច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា<br>- ប្រកាសអន្តរក្រសួង លេខ ៨២៥ សហវ ប្រក.ចមព ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៧ ស្ដីពីកម្រៃសេវាតម្កល់ និងស្រាវជ្រាវរកលិខិតជូនដំណឹង នៃប្រតិបត្តិការដែលមានកិច្ចធានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម។ លិខិតជូនដំណឹង លេខ ៣០៥៨ ពណ.នតក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ ស្ដីពីការតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា និងការស្រាវជ្រាវរកកំណត់ត្រា តាមមធ្យោបាយអេឡិចត្រូនិច របស់ក្រសួងពាណិជ្ជកម្ម។ |
| អតិថិជនដែលមានសិទ្ធិ<br>ទទួលសេវា | រូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរ ឬ បរទេស |
| ស្តង់ដារសេវា | - ព្រះរាជក្រមលេខ នស/រកម/០៥០៧/០១២ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៧ ស្ដីពីការប្រកាសឱ្យប្រើនូវច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា<br>- ប្រកាសអន្តរក្រសួង លេខ ៨២៥ សហវ ប្រក.ចមព ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ |

| | |
|---|---|
| | ២០០៧ ស្តីពីកម្រៃសេវាតម្កល់ និងស្រាវជ្រាវរកលិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។<br>- លិខិតជូនដំណឹង លេខ ៣០៩៨ ពណ.នតក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការ តម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា និងការស្រាវជ្រាវរក កំណត់ត្រាតាមមធ្យោបាយអេឡិចត្រូនិចរបស់ក្រសួងពាណិជ្ជកម្ម ។ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរសម្រាប់ពលរដ្ឋខ្មែរ<br>- លិខិតឆ្លងដែនសម្រាប់ពលរដ្ឋបរទេស<br>- លិខិត ឬវិញ្ញាបនបត្រចុះបញ្ជីសម្រាប់នីតិបុគ្គល |
| យោបល់ | - ការមិនបានមកតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានានឹងនាំឱ្យបាត់បង់នូវអត្ថិភាពលើទ្រព្យធានាកាតព្វកិច្ច ។<br>- អាចបង្កឱ្យមានវិវាទលើការទាមទារទ្រព្យធានាដែលមានម្ចាស់បំណុលលើសពីម្នាក់ |
| បច្ចុប្បន្នភាពព័ត៌មាន | - ក្រសួងពាណិជ្ជកម្មបានដំណើរការសេវានេះ ដោយបានបង្កើតការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា និងបង្កើតគេហទំព័រ www.setfo.gov.kh ដែលកំពុងបានដំណើរការរួចហើយ ។<br>- សេវានេះដំណើរការតាមប្រព័ន្ធអេឡិចត្រូនិកទាំងការតម្កល់លិខិតជូនដំណឹង និងការ បង់ប្រាក់កម្រៃជូនរដ្ឋតាមប្រកាសអន្តរក្រសួង ។ |